ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីជូនព័ត៌មាន
ស្តីពីលទ្ធផលនៃវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីតំបន់មេគង្គ
កិច្ចប្រជុំកំពូលយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ លើកទី ៧
និងកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ារ-វៀតណាម លើកទី ៨
*ថ្ងៃទី ២៤-២៦ ខែ តុលា ឆ្នាំ ២០១៦*
ទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម
*****

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចូលរួម "វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីតំបន់មេគង្គ" "កិច្ចប្រជុំកំពូលស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (អេកម៉ិក) លើកទី ៧" និង "កិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ារ-វៀតណាម (CLMV) លើកទី ៨" នៅទីក្រុងហាណូយ ប្រទេសវៀតណាម តាមការអញ្ជើញរបស់ឯកឧត្តម ង្វៀន សួនហ្វ៊ុក នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

<u>វេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីតំបន់មេគង្គ</u>

វេទិកានេះមានការចូលរួមពីភាគីរដ្ឋាភិបាល ដឹកនាំដោយប្រមុខរដ្ឋ/រដ្ឋាភិបាលប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ និងវៀតណាម តំណាងវេទិកាសេដ្ឋកិច្ចពិភពលោក និងគណៈប្រតិភូដទៃទៀតពីផ្នែកឯកជននៃបណ្តាប្រទេសមេគង្គ។ ដោយបញ្ជាក់ពីសក្តានុពលសេដ្ឋកិច្ចដ៏ទូលំទូលាយ និងសារៈសំខាន់នៃតួនាទីរបស់តំបន់ទន្លេមេគង្គ ថ្នាក់ដឹកនាំបានផ្លាស់ប្តូរយោបល់ស្តីពីមធ្យោបាយនានាក្នុងការពង្រឹងការតភ្ជាប់តំបន់ លើកកម្ពស់ការធ្វើសមាហរណកម្មពាណិជ្ជកម្ម និងសេដ្ឋកិច្ចនៅក្នុងក្របខណ្ឌនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ក៏ដូចជាការពង្រឹងខ្សែចង្វាក់ផលិតកម្មតំបន់ និងស្វែងរកគំរូថ្មី ៗ សម្រាប់ឧស្សាហកម្មនៅតំបន់មេគង្គ ដោយការជួយគ្នាទៅវិញទៅមករវាងប្រទេសនីមួយ ៗ។

នៅក្នុងសុន្ទរកថាដែលបានថ្លែងនៅក្នុងពិធីបើកវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពី "ការស្វែងរកជោគជ័យរួមគ្នា៖ ថ្នាក់ដឹកនាំតំបន់ចែករំលែកទស្សនវិស័យសម្រាប់តំបន់មេគង្គ" សម្តេចតេជោនាយករដ្ឋមន្ត្រី បានបង្ហាញពីទស្សនវិស័យរបស់សម្តេចតេជោចំពោះទិសដៅអភិវឌ្ឍន៍តំបន់មេគង្គ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានទទួលស្គាល់ពីសក្តានុពលដ៏ធំធេងនៃតំបន់ថាជាបណ្តាញផលិតកម្មតំបន់ដែលមានប្រសិទ្ធភាពខ្ពស់មួយ ប៉ុន្តែបញ្ហាប្រឈមនៅតែមាន ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាធំ ៗ ចំពោះភាពប្រកួតប្រជែងតំបន់។



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានលើកទឹកចិត្តឱ្យវិស័យឯកជនដើរតួនាទីយ៉ាងសកម្មថែមទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តាមរយៈគម្រោងភាពជាដៃគូរដ្ឋ និងឯកជន ដូចជា គម្រោងផ្លូវហាយវេ ផ្លូវរថភ្លើង ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស ក៏ដូចជា បណ្តាញថាមពល និងបណ្តាញទូរគមនាគមន៍ ដោយយកចិត្តទុកដាក់លើយន្តការហិរញ្ញវត្ថុថ្មីដូចជា "**គំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់មួយ វិថីមួយ**" របស់ប្រទេសចិន ដែលរួមមានមូលនិធិវិថីសូត្រ និងធនាគារវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) និង "**ភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព**" របស់ប្រទេសជប៉ុន ក៏ដូចជាស្ថាប័នហិរញ្ញវត្ថុពហុភាគីដទៃទៀត។

ក្នុងន័យនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី**ក៏មានការយកចិត្តទុកដាក់ឱ្យកម្ពុជាធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេសនៅតំបន់មេគង្គនៅក្នុងផ្នែកជាច្រើននៃវិស័យផលិតកម្ម ឧស្សាហកម្ម និងខ្សែចង្វាក់ផលិតកម្មតំបន់ តាមរយៈការអនុវត្តនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**ក៏បានបញ្ជាក់ពីតម្រូវការនៃកិច្ចសហប្រតិបត្តិការច្រើនថែមទៀតនៅក្នុងវិស័យនាំចេញផលិតផលកសិកម្ម ជាពិសេសគឺការនាំចេញអង្ករ។

ជាទីបញ្ចប់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានប្រកាសថា កម្ពុជានឹងទទួលរៀបចំវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាន នៅខែ ឧសភា ឆ្នាំ ២០១៧ នៅទីក្រុងភ្នំពេញ និងបានអញ្ជើញអ្នកចូលរួមទាំងអស់ចូលរួមវេទិកានេះ។

## <u>កិច្ចប្រជុំកំពូលអេកម៉ិកលើកទី ៧ និងកិច្ចប្រជុំកំពូល CLMV លើកទី ៨</u>

កិច្ចប្រជុំកំពូលយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (អេកម៉ិក) និងកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-មីយ៉ាន់ម៉ារ-វៀតណាម (CLMV) ត្រូវបានរៀបចំឡើងបន្តបន្ទាប់គ្នា នាថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ និងមានការអញ្ជើញចូលរួមពីប្រមុខរដ្ឋ/រដ្ឋាភិបាលនៃប្រទេសអេកម៉ិក និង CLMV រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ារ ថៃ និងវៀតណាម។ អគ្គលេខាធិការសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាលេខាប្រតិបត្តិគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) តំណាងធនាគារអភិវឌ្ឍន៍អាស៊ី និងតំណាងធនាគារពិភពលោក ក៏មានវត្តមានក្នុងកិច្ចប្រជុំកំពូលទាំងពីរនេះផងដែរ។

កិច្ចប្រជុំកំពូលអេកម៉ិកលើកទី ៧ នេះត្រូវបានរៀបចំឡើងក្រោមប្រធានបទ "**ឆ្ពោះទៅរកអនុតំបន់មេគង្គប្រកបដោយថាមភាព និងវិបុលភាព - ការពង្រឹងការតភ្ជាប់តំបន់ដើម្បីជំរុញសមាហរណកម្មសេដ្ឋកិច្ចអេកម៉ិក និងកិច្ចសហប្រតិបត្តិការអេកម៉ិក សម្រាប់ការអភិវឌ្ឍអនុតំបន់មេគង្គប្រកបដោយចីរភាព**"។ នៅក្នុងសុន្ទរកថា **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានលើកឡើងនូវចំណុចពាក់ព័ន្ធជាច្រើនដែលមានផលប្រយោជន៍ដល់កម្ពុជា ក៏ដូចជាប្រទេសអេកម៉ិកទាំងមូល ដូចជា ការគ្រប់គ្រងលំហូរពលករ ការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកផលិតកម្ម និងពាណិជ្ជកម្មស្រូវ-អង្ករ ការបង្កើតបណ្តាញផលិតកម្មតំបន់ និងការប្រែប្រួលអាកាសធាតុ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**ក៏បានចែករំលែកទស្សនៈវិស័យស្តីពីទិសដៅអនាគតរបស់អេកម៉ិក ដោយសង្កត់ធ្ងន់លើការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការតភ្ជាប់ផ្នែកថាមពល និងឌីជីថល ការសម្របសម្រួលនិយ័តកម្ម និងស្ថាប័ន។ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានជំរុញឱ្យអេកម៉ិកកំណត់ និងអភិវឌ្ឍរួមគ្នានូវខ្សែចង្វាក់ទំនិញ និងសេវាកម្មសម្រាប់អនុតំបន់ ក៏ដូចជា ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងចំណោមធុរជន និងរវាងប្រជាជន និងប្រជាជន។

ថ្នាក់ដឹកនាំប្រទេសអេកម៉ិកបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងហាណូយ នៃកិច្ចប្រជុំកំពូលអេកម៉ិក លើកទី ៧ ដែលក្នុងនោះថ្នាក់ដឹកនាំប្តេជ្ញាចិត្តក្នុងការចាត់វិធានការដូចតទៅ៖ ១). សម្រួលកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការបញ្ចប់ការតភ្ជាប់ការដឹកជញ្ជូនពហុគំរូ និងប្រើប្រាស់យ៉ាងពេញលេញនូវបណ្តាញផ្លូវដឹកជញ្ជូន និងរបៀងសេដ្ឋកិច្ចនានាដែលមានស្រាប់ ជាពិសេស របៀងសេដ្ឋកិច្ចខាងត្បូង និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការធ្វើសុខដុមនីយកម្ម និងសាមញ្ញកម្មច្បាប់ និងបទប្បញ្ញត្តិនានា ២). ពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម តាមរយៈការអភិវឌ្ឍចង្កោមសហគ្រាសធុនតូច និងមធ្យម សុខដុមនីយកម្មមាត្រដ្ឋាន ការសម្រួលដល់ការចូលយកព័ត៌មាន ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព ៣). ពន្លឿនការអនុវត្តកិច្ចសហប្រតិបត្តិការទាំង ៧ ចំណុច នៅក្នុងផែនការសកម្មភាពទេសចរណ៍អេកម៉ិកឆ្នាំ ២០១៦-២០១៨ និងជំរុញទេសចរណ៍បៃតង និងប្រកបដោយការទទួលខុសត្រូវក្នុងប្រទេសអេកម៉ិក ៤). ជំរុញការអភិវឌ្ឍកសិកម្មតាមកិច្ចសន្យាទ្វេភាគី និងពហុភាគី ដើម្បីបង្កើតការងារ និងបង្កើនសុខុមាលភាពរបស់កសិករ ៥). ជំរុញពាណិជ្ជកម្មលើផលិតផលកសិកម្ម និងការផ្លាស់ប្តូរទំនាក់ទំនងស្តីពីផលិតកម្ម និងពាណិជ្ជកម្មអង្ករ និង ៦). ប្តេជ្ញាចិត្តក្នុងការធ្វើសមាហរណកម្មគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលពាក់ព័ន្ធ ទៅក្នុងគ្រប់គម្រោងអភិវឌ្ឍសេដ្ឋកិច្ចទាំងអស់របស់អេកម៉ិក។

កិច្ចប្រជុំកំពូល CLMV លើកទី ៨ ត្រូវបានរៀបចំឡើងក្រោមប្រធានបទ "ចាប់យកឱកាស កសាងអនាគត៖ កាលានុវត្តភាព និងបញ្ហាប្រឈមសម្រាប់ភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងសមាហរណកម្មតំបន់របស់ CLMV"។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ពីតម្រូវការរបស់ប្រទេស CLMV ក្នុងការសម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធលើបញ្ហាផលិតផលកសិកម្ម ខណៈដែលប្រទេសទាំងនេះកំពុងប្រកួតប្រជែងជាមួយគ្នាឯងក្នុងការផលិត និងនាំចេញទៅកាន់ប្រទេសអភិវឌ្ឍន៍ ជាពិសេសផលិតផលកសិកម្ម ដែលធ្វើឱ្យផលិតផលទាំងនោះធ្លាក់ថ្លៃ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់បន្ថែមពីកិច្ចសហប្រតិបត្តិការលើ វិស័យទេសចរណ៍ដែលជាចំណុចខ្លាំងពីធម្មជាតិរបស់ប្រទេស CLMV។

ថ្នាក់ដឹកនាំប្រទេស CLMV បានអនុម័តសេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូល CLMV លើកទី ៧ ដែលរំលេចឱ្យឃើញពីតម្រូវការក្នុងការបន្តធ្វើឲ្យកំណែទម្រង់រចនាសម្ព័ន្ធនៃសេដ្ឋកិច្ចរបស់យើងឈានទៅមុខ និងការជំរុញការតភ្ជាប់តំបន់ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់ CLMV ។ ថ្នាក់ដឹកនាំបានឯកភាពអនុវត្តវិធានការជាក់លាក់ ដូចតទៅ៖ ១). ពន្លឿនការសាងសង់តំណផ្លូវដែលមិនទាន់តភ្ជាប់ និងកែលម្អផ្លូវនៅតាមរបៀងសេដ្ឋកិច្ចនានា និងសម្រួលដល់ការដឹកជញ្ជូនតាមផ្លូវអាកាស ២). ប្រែក្លាយរបៀងដឹកជញ្ជូនទៅជារបៀងសេដ្ឋកិច្ច និងឧស្សាហកម្ម ដោយពន្លឿនការធ្វើសាមញ្ញកម្ម និងសុខដុមនីយកម្មនៃនីតិវិធីឆ្លងកាត់ព្រំដែន ៣). ជំរុញគោលនយោបាយកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍឧស្សាហកម្ម ការធ្វើឲ្យមានមាត្រដ្ឋាន និងអនុលោមភាព សហគ្រាសធុនតូច និងមធ្យម និងការអភិវឌ្ឍធនធានមនុស្សដែលមានគុណភាពខ្ពស់ និង ៤). អនុវត្តផែនការសកម្មភាពឆ្នាំ ២០១៦-២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងបណ្តាប្រទេស CLMV ។

ថ្នាក់ដឹកនាំប្រទេសជាសមាជិកបានសម្រេចរៀបចំកិច្ចប្រជុំកំពូលអេកម៉ិក លើកទី ៨ និងកិច្ចប្រជុំកំពូល CLMV លើកទី ៩ បន្តបន្ទាប់គ្នា នៅព្រះរាជាណាចក្រថៃ នាឆ្នាំ ២០១៨។ កម្ពុជានឹងធ្វើជាប្រធានកិច្ចប្រជុំកំពូល CLMV លើកទី ៩ ខណៈប្រទេសថៃនឹងធ្វើជាប្រធានកិច្ចប្រជុំកំពូលអេកម៉ិកលើកទី ៨។

## ជំនួបទ្វេភាគីដទៃទៀត

មុនកិច្ចប្រជុំកំពូលអេកម៉ិក និង CLMV សម្តេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមពិសាអាហារការងារពេលព្រឹក រៀបចំដោយឯកឧត្តមនាយករដ្ឋមន្ត្រី ង្វៀន សួនហ៊្វុក ដែលក្នុងឱកាសនោះ ថ្នាក់ដឹកនាំទាំងពីរមានឱកាសពិភាក្សាបញ្ហាទ្វេភាគីដែលមានផលប្រយោជន៍ទៅវិញទៅមក។ នាយករដ្ឋមន្ត្រីប្រទេសទាំងពីរក៏បានអញ្ជើញធ្វើជាសាក្សីនៃពិធីចុះហត្ថលេខាលើកិច្ចសម្របសម្រួលស្តីពីការពង្រឹងពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងវៀតណាមផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦